## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ៤៤..អនក្រ. បក

# អនុក្រឹត្យ
## ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១០៩៤/៨៣ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស /រកត /១០៩៤ /៩០ចុះថ្ងៃទី៣១ ខែតុលាឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស /រកម /០១៩៦ /២២ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងកិច្ចការនារី ។
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បកចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៨៩៧ /១៥៧ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី
- តាមការអនុម័តរបស់គណៈរដ្ឋមន្ត្រីនាថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ១៩៩៨

# សំរេច

## ជំពូក១

## បទបញ្ញត្តិទូទៅ

មាត្រា១: អនុក្រឹត្យនេះរៀបចំបណ្តាអង្គភាពនៃក្រសួងកិច្ចការនារី និងកំណត់បេសកកម្ម របស់ក្រសួងនិងមុខការនៃអគ្គនាយកដ្ឋាននិងនាយកដ្ឋាននានា។

## ជំពូក២

## បេសកកម្ម និងរចនាសម្ព័ន្ធ

មាត្រា២: ក្រសួងកិច្ចការនារីត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្មអោយដឹកនាំ និងគ្រប់គ្រងលើវិស័យកិច្ចការនារី នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៣: ក្រសួងកិច្ចការនារីមានមុខងារនិងភារៈកិច្ចដូចតទៅ ៖

- រៀបចំនិងអនុវត្តនយោបាយជាតិសំរាប់លើកកំពស់តួនាទីនារី ។
- ជំរុញវិធានសមស្របក្នុងការការពារនិងធានាការគោរពសិទ្ធិនារីក្នុងរង្វង់គ្រួសារ ឬទីកន្លែងធ្វើការនិងក្នុងសង្គម ។
- ជំរុញអត្រានារី អោយកាន់តែកើន នៅក្នុងការងារនយោបាយ សេដ្ឋកិច្ច តុលាការ ឃោសនា អប់រំ វប្បធម៌ និងការងារអភិវឌ្ឍន៍សង្គម ។
- លើកគោលការណ៍ណែនាំនារី ជាមាតាអោយយល់ពីតំលៃកាតព្វកិច្ច តួនាទីក្នុងគ្រួសារ និងក្នុងសង្គមដើម្បីទទួលបានសុភមង្គល ។
- ត្រួតពិនិត្យ សកម្មភាព និងជួយសំរួលការប្រព្រឹត្តទៅរបស់សមាគមនិងអង្គការ មិនមែនរដ្ឋាភិបាលដែលបំរើផលប្រយោជន៍នារី ។
- លើកគោលការណ៍ និងកម្មវិធីផ្សព្វផ្សាយ កម្មវិធីវេទយិកកម្ម កម្មវិធីអប់រំ កម្មវិធីបណ្តុះបណ្តាល ពីចំណេះដឹងចាំបាច់ជាមូលដ្ឋានដល់នារី នៅទីក្រុង និងជនបទ ដើម្បីជួយអោយអភិវឌ្ឍន៍ខ្លួនឯងបានដោយសហការជាមួយស្ថាប័ន ពាក់ព័ន្ធ និងអង្គការអន្តរជាតិនានា ។

- ពង្រឹង និងពង្រីកវិស័យនារី ក្នុងការអភិវឌ្ឍន៍ដោយសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិនានា។

- ចុះកិច្ចព្រមព្រៀងជាមួយបណ្តាប្រទេស អង្គការជាតិនិងអង្គការអន្តរជាតិពាក់ព័ន្ធ និងបញ្ហានារី ក្រោយពីបានការឯកភាពពីរាជរដ្ឋាភិបាល ។

- កសាងស្ថិតិ និងឯកសារច្បាប់ ទាក់ទងនឹងកិច្ចការនារី ។

- អប់រំផ្សព្វផ្សាយដល់សង្គមអោយយល់ដឹងថាបុរសនិងស្ត្រីជាដៃគូរក្នុងការងារក្នុងគ្រួសារក៏ដូចជាការងារក្នុងសហគមន៍ និងក្នុងសង្គមជាតិដែរ ។

- លើកវិធានការលុបបំបាត់ការជួញដូរនារីនិងកុមារ និងលើកវិធានការទប់ស្កាត់កុំអោយនារីធ្វើពេស្យាចារដើម្បីរស់ ។

- ប្រារព្ធទិវាអន្តរជាតិនារី ។

- អនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារី ដែលកម្ពុជាបានសច្ចាប័ន ពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ ។

**មាត្រា៤:** ក្រសួងកិច្ចការនារីមានរចនាសម្ព័ន្ធ ដូចតទៅ ៖

- អគ្គាធិការដ្ឋាន
- អគ្គនាយកដ្ឋានកិច្ចការនារី មាននាយកដ្ឋាន៤ :
  - នាយកដ្ឋាន សុខភាព និងសកម្មភាពសង្គម
  - នាយកដ្ឋាន ផ្សព្វផ្សាយ អប់រំ និងបណ្តុះបណ្តាល
  - នាយកដ្ឋាន អភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ និង
  - នាយកដ្ឋាន ផែនការ និងសិក្សាអំពីនារី
- នាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អង្គភាពមូលដ្ឋាន : មន្ទីរកិច្ចការនារីខេត្ត ក្រុង ។

អង្គការលេខរបស់ក្រសួងកិច្ចការនារី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូក៣

## អគ្គាធិការដ្ឋាន

មាត្រា៥: អគ្គាធិការដ្ឋានទទួលបន្ទុក ៖

- ធ្វើអធិការកិច្ចជាប្រចាំលើគ្រប់អង្គភាពក្រោមឱវាទក្រសួងកិច្ចការនារី ។
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីពីការប្រព្រឹត្តទៅរបស់អង្គភាព ដែលបានធ្វើអធិការកិច្ចហើយនោះ និងពីមធ្យោបាយ កែលំអអំពីការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ។
- ប្រតិបត្តិភារកិច្ចតាមកាលដែលរដ្ឋមន្ត្រីបានប្រគល់ទំនុកចិត្ត ។

អគ្គាធិការដ្ឋានត្រូវបានដឹកនាំដោយអគ្គាធិការមួយរូបនិងអមដោយអគ្គាធិការរងជាជំនួយ ការតាមការចាំបាច់ ។

## ជំពូក៤

## អគ្គនាយកដ្ឋានកិច្ចការនារី

មាត្រា៦: អគ្គនាយកដ្ឋានកិច្ចការនារី ទទួលបន្ទុកធ្វើទំនាក់ទំនងសំរបសំរួល គ្រប់គ្រងកិច្ចការ សុខភាព សកម្មភាពសង្គម ផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល អភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ ផែនការ និងសិក្សាអំពីនារី ។

អគ្គនាយកដ្ឋានកិច្ចការនារីដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករងជាជំនួយការតាមការចាំបាច់។ អគ្គនាយកដ្ឋាននេះមាននាយកដ្ឋានចំនួន៤ដូចមានចែងក្នុងមាត្រាខាងក្រោម៖

មាត្រា៧: នាយកដ្ឋាន សុខភាព និងសកម្មភាពសង្គម ទទួលបន្ទុក:

- ពង្រីកផ្នែកសុខភាពដែលទាក់ទងនឹងនារី មាតា និងទារក ដោយផ្តល់ព័ត៌មានស្តីអំពីការអប់រំ និងផ្តល់សេវាកម្មចាំបាច់សំរាប់នារី និងគ្រួសារលើបញ្ហាសុខភាពបឋម ជាពិសេសសុខភាពបន្តពូជ តាមរយៈការបណ្តុះបណ្តាលនារីស្ម័គ្រចិត្តតាមខេត្ត ក្រុង និងសហគមន៍នានាដោយសហការ

ជាមួយក្រសួងពាក់ព័ន្ធលើវិស័យបច្ចេកទេស ជាពិសេសក្រសួងសុខាភិបាល។

- រៀបចំអោយមានមជ្ឈមណ្ឌល ថែទាំកុមារនៅគ្រប់ខេត្ត ក្រុងដោយសហការជាមួយក្រសួងពាក់ព័ន្ធ ។
- ពិគ្រោះនិងផ្តល់យោបល់ដល់នារីរងគ្រោះព្រមទាំងជួយរកដំណោះស្រាយសមស្របតាមផ្លូវសម្រុះសម្រួលគ្រួសារ និងបញ្ជូនសំណុំរឿងតាមផ្លូវច្បាប់ ។
- លើកវិធានការប្រឆាំងនឹងអំពើហិង្សាលើនារី និងអនុវត្តវិធានការនេះដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។
- លើកវិធានការលុបបំបាត់ការជួញដូរនារីនិងកុមារ និងអនុវត្តវិធានការនេះដោយ សហការជាមួយស្ថាប័នពាក់ព័ន្ធ ។
- លើកវិធានការទប់ស្កាត់ កុំអោយនារីលក់ខ្លួនធ្វើពេស្យាចារដើម្បីរស់ ។
- លើកវិធានការជួយអប់រំនារីដែលមានវិបត្តិផ្លូវចិត្ត ។
- លើកវិធានការបំបាត់ការរំលោភសិទ្ធិនារី ជាអាទិ៍រឿងអាស្រូវទាំងឡាយក្នុងគ្រួសារ ក្នុងកន្លែងធ្វើការក្នុងរោងចក្រ ក្នុងសហគ្រាសនានានិងអនុវត្តវិធានការទាំងនេះដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

**មាត្រា៨:** នាយកដ្ឋាន ផ្សព្វផ្សាយ អប់រំ និងបណ្តុះបណ្តាល ទទួលបន្ទុក:

- ទទួលខុសត្រូវចំពោះការអប់រំ និងការបណ្តុះបណ្តាលនារីនៅជនបទ តាមកម្មវិធីជាអាទិភាព ។
- លើកគំរោងបណ្តុះបណ្តាលចំណេះដឹងទូទៅជាមូលដ្ឋានដល់នារីតាមជនបទដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ពិសេសជាមួយក្រសួងអប់រំ យុវជននិងកីឡានិងជាមួយអង្គការមិនមែនរដ្ឋាភិបាលនានានិងអនុវត្តគំរោងការនេះ។
- ទ្រទ្រង់តួនាទីរបស់នារី និងកុមារីតាមរយៈកម្មវិធីសិក្សា ជាអាទិ៍សហការរៀបចំ កម្មវិធីអប់រំនារីវ័យចំណាស់ជាមួយនាយកដ្ឋាន អប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជននិងកីឡា និងក្រសួងស្ថាប័នពាក់ព័ន្ធ ។
- លើកកំពស់ចំណេះដឹងពី យេនឌ័រ (Gender) ដល់មន្ត្រីរាជការរបស់ជាអាទិ៍លើកកំពស់តាមរយៈការអប់រំបណ្តុះបណ្តាលដែលឧបត្ថម្ភដោយបណ្តាប្រទេសផ្តល់ជំនួយ ។
- អប់រំបណ្តុះបណ្តាលវិជ្ជាជីវៈឈរលើមូលដ្ឋានតម្រូវការទីផ្សារពលកម្ម ។

- ចងក្រងឯកសារស្ដីពីសកម្មភាពនយោបាយ សេដ្ឋកិច្ច វប្បធម៌របស់នារី។

- ធ្វើការផ្សព្វផ្សាយ តាមរយៈវិទ្យុ ទូរទស្សន៍ ទស្សនាវដ្ដី ព្រឹត្តិប័ត្រ ផ្ទាំងរូបភាព រូបថត និងឯកសារសំខាន់ៗ ដើម្បីអប់រំដល់មហាជន ជាពិសេសនារី និងតាមដានប្រសិទ្ធិភាពការងារនេះ ។

- បោះពុម្ពផ្សាយពីគោលនយោបាយជាតិសំរាប់នារី ក្រមនារីនិងអត្ថបទច្បាប់ ព្រមទាំងបង្ករលក្ខណៈយល់ដឹង ដែលទាក់ទងនិងនារីភេទដោយសហការណ៍ ជាមួយក្រសួង ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិ។

- រៀបចំ និងគ្រប់គ្រងបណ្ណាល័យមួយដោយប្រមូលថែរក្សាឯកសារ លិខិតបទដ្ឋាន ច្បាប់ប្រពៃណី ប្រវត្តិសាស្ត្រដែលទាក់ទងបញ្ហា និងតួនាទីនារី។

មាត្រា៩: នាយកដ្ឋាន អភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ ទទួលបន្ទុកៈ

- បំផុសគំនិត និងបង្ករលក្ខណៈដោយផ្ដល់ជាទុន និងបច្ចេកទេសលើការ ដាំដុះ ការចិញ្ចឹមសត្វ ជាលក្ខណៈគ្រួសារ និងជាលក្ខណៈសហគម ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល ។

- ផ្ដួចផ្ដើមឆ្នៃប្រឌិតជាសហគ្រាសខ្នាតតូច ។

- ណែនាំកែច្នៃសិប្បកម្ម ចាប់ពីធ្វើដោយដៃ រហូតដល់ពាក់កណ្ដាលស្វ័យប្រវត្តិ ។

- លើកកំពស់ជីវភាពគ្រួសារនៅមូលដ្ឋាន ដោយសហការជាមួយក្រសួង ស្ថាប័ននិង អង្គការនានា អោយគេជួយពង្រីកមុខរបរជួយធ្វើសហគ្រាសខ្នាតតូច ជួយបង្កើនកសិផលដល់គ្រួសារតាមរយៈការខ្ចីទុនមានការប្រាក់ទាបបំផុត ។

- លើកកំពស់ការយល់ដឹងពីជំនាញឥណទាន នៃភ្នាក់ងារឥណទានរបស់ក្រសួង។

មាត្រា១០: នាយកដ្ឋានផែនការ និងសិក្សាអំពីនារី ទទួលបន្ទុកៈ

- រៀបចំគំរោងផែនការ និងកម្មវិធីអភិវឌ្ឍន៍នារី ស្របតាមវិធានការស្ដារនិងអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ។

- រៀបចំគំរោងកម្មវិធីវិនិយោគសាធារណៈ ធ្វើសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលដើម្បីសំរបសំរួលផលប្រយោជន៍ដល់នារីទូទៅ ។

- រៀបចំផែនការប្រចាំឆ្នាំសំរាប់ការសិក្សាពីសេដ្ឋកិច្ច សង្គម ដើម្បីគាំទ្រវិធានការ និងកម្មវិធីរបស់នារី ។
- រៀបចំផែនការអភិវឌ្ឍន៍នារីទូទាំងប្រទេសដោយសហការជិតស្និតជាមួយសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ ។
- ប្រមូល និងវិភាគស្ថិតិនារី តាមប្រភេទមន្ត្រីរាជការ និយោជិតកម្មករនៅទូទាំងប្រទេស ។
- ប្រមូលដកស្រង់ ចងក្រង និងផ្សព្វផ្សាយច្បាប់ ដែលទាក់ទងទៅនឹងនារី។
- ត្រួតពិនិត្យ វាយតម្លៃការអនុវត្តន៍ផែនការសកម្មភាព និងរៀបចំទិសដៅអភិវឌ្ឍន៍នារី ។

## ជំពូកទី៥

## នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

មាត្រា១១: នាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ ទទួលបន្ទុក ៖

ក. ការគ្រប់គ្រងបុគ្គលិក

- គ្រប់គ្រងផ្នែករដ្ឋបាលលើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈរបស់ក្រសួង ដោយទំនាក់ទំនង និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។
- រៀបចំរាល់លិខិតរដ្ឋបាលសំរាប់ការគ្រប់គ្រងអាជីព ។
- ធ្វើកម្មវិធីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង ។
- វាយតំលៃតំរូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក ។
- រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្តដោយទំនាក់ទំនងនិងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអនុវត្តន៍នយោបាយនោះ ។
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពត៌មានប្រតិបត្តិ ។
- គ្រប់គ្រងការងារសង្គមរបស់ក្រសួង ។

ខ. ការគ្រប់គ្រងរដ្ឋបាលទូទៅ

- សំរបសំរួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាលនិងអង្គភាពមូលដ្ឋាន ។

- គ្រប់គ្រងនិងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។
- ធានាប្រសិទ្ធិភាព សុវត្ថិភាពរដ្ឋបាល ។
- សរុបនិងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង ។

គ. ការគ្រប់គ្រងសំភារៈនិងបរិក្ខារ

- ប្រមូលផ្តុំតំរូវការបរិក្ខារ ធ្វើកម្មវិធីចំណាយគ្រប់គ្រងការរៀបចំផ្គត់ផ្គង់ សំភារៈ និងបរិក្ខារ របស់ក្រសួង ។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈនិងធ្វើបញ្ជីសារពើភ័ណ្ឌ។
- គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួងព្រមទាំងធ្វើកម្មវិធី ចំណាយនិងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់ ។
- ទទួលបែងចែកបរិក្ខារជូនដល់អង្គភាពបណ្តាខេត្ត-ក្រុងនានា ។
- កាន់បញ្ជីជាប្រចាំនូវសាលាកប័ត្រ និងគណនេយ្យរូបធាតុ ។
- ពង្រឹងមានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។
- ត្រួតពិនិត្យបច្ចេកទេស នៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។

ឃ. ការគ្រប់គ្រងបន្ទុកគណនី និងហិរញ្ញវត្ថុ

- លើកគំរោងថវិកាក្រសួង តាមដានលើកពីការប្រតិបត្តិ ។
- ប្រមូលផ្តុំ និងសំរបសំរួលជំពូកថវិកា ។
- តាមដានលើកការគ្រប់គ្រងគណនីពិសេស ។
- ប្រមូលផ្តុំ និងសំរបសំរួល រាល់ការចំណាយរបស់ក្រសួង ។
- គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តលទ្ធកម្មសាធារណៈ ។
- ប្រមូលចំណូលអោយបានសមស្រប តាមច្បាប់ហិរញ្ញវត្ថុដែលបានកំណត់ ។

## ជំពូក៦

## ខុទ្ទកាល័យរដ្ឋមន្ត្រី

មាត្រា១២: ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយដែលកំណត់តាមបទបញ្ញត្តិ នៃអនុក្រឹត្យលេខ២០អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមាន

យោងក្នុងមូលបទ ខាងលើស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូក៧

## អង្គភាពមូលដ្ឋាន

មាត្រា១៣ : នៅតាមខេត្ត-ក្រុងនិមួយៗ មានមន្ទីរកិច្ចការនារីខេត្ត-ក្រុងទទួលបន្ទុកអនុវត្ត និងសំរបសំរួលសកម្មភាពរបស់ក្រសួង ។

## ជំពូក៨

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា១៤. អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ញត្តិកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ខែវិច្ឆិកាឆ្នាំ១៩៩៥ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកានៅតាមបណ្តាក្រសួង។

## ជំពូក៩

## អវសានបញ្ញត្តិ

មាត្រា១៥. ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង នៅរដ្ឋបាលកណ្តាលចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ។

មាត្រា១៦. បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា១៧_ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា១៨_ អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ,ថ្ងៃទី ២៩ ខែ មករា ឆ្នាំ១៩៩៨

**នាយករដ្ឋមន្ត្រីទី១** **នាយករដ្ឋមន្ត្រីទី២**

**អ៊ឹង ហួត** **ហ៊ុន សែន**

បានជំរាបជូន
ឯកឧត្តមនាយករដ្ឋមន្ត្រីទី១
សម្តេចនាយករដ្ឋមន្ត្រីទី២

**រដ្ឋលេខាធិការក្រសួងកិច្ចការនារី ស្តីទី**

ស្រាវ ស៊ុន

ចម្លងជូន
-ខុទ្ទកាល័យព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី១
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
-គ្រប់សាលាខេត្ត-ក្រុង
-ដូចមាត្រា ១៧
-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ២៤ អនក្រ.បក

ថ្ងៃទី២៥... ខែ មេសា ឆ្នាំ១៩៩៩

# អង្គការលេខរបស់ក្រសួងកិច្ចការនារី

